# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំឆមាសទី១ ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងឆមាសទី១ ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិបានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-អគ្គលេខាធិការធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានដំណើរការងាររបស់ខ្លួនដោយក្នុងនោះអគ្គលេខាធិការដ្ឋានបានទទួលនូវលិខិតចូលចំនួន ១៣១ លេខ ពីគ្រប់បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ជំនួយដៃគូអភិវឌ្ឍន៍ បណ្តាស្ថានទូតនានា និងជាពិសេសស្ថាប័នពាក់ព័ន្ធវិស័យតុលាការ

-ចំពោះលិខិតចេញវិញក្នុងកំឡុងឆមាសទី១ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានផ្ញើលិខិតចេញបានចំនួនៈលិខិតស្នើផ្សេងៗចំនួន ៣៥លេខ លិខិតអញ្ជើញចូលរួមប្រជុំ ១០លេខ របាយកាណ៍ និងកំណត់ហេតុបានចំនួន ១០លេខ ក្នុងនោះបានផ្ញើទៅក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល បណ្តាស្ថានទូត ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធវិស័យតុលាការ

**ខ.ការពង្រឹងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន និងការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ខ១.បានធ្វើការបណ្តុះបណ្តាលមន្ត្រីរបស់អគ្គលេខាធិការដ្ឋានៈ**

-បានបញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋានចំនួន ០៩ រូបដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលភាសារអង់គ្លេសនៅសាលា (ELT) ដែលនឹងត្រូវបញ្ចប់នៅដំណាច់ខែមីនា ឆ្នាំ២០១០

-បានបញ្ជូនមន្ត្រី ០១រូប ដើម្បីចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជន់ខ្ពស់សម្រាប់ឆ្នាំ២០១០

-បានបញ្ជូនមន្ត្រី ០៤ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីប្រើប្រាស់ (UNICODE) ដែលរៀបចំឡើងដោយ (NIDA)

-បានបញ្ជូនមន្ត្រី ០១ រូប របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីធនធានសេនេទិច និងកម្មសិទ្ធិបញ្ញានៅទីក្រុង Alarp ប្រទេសស៊ុយអែត រយៈពេល ១៥ ថ្ងៃ ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០

**ខ២.ការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ៈ**

-បានបោះពុម្ពចែកផ្សាយនូវព្រឹត្តប័ត្រកំណែទម្រង់ច្បាប់ និងតុលាការលេខ០៣ ឆ្នាំទី២ ផ្ញើជូនដល់គ្រប់ក្រសួងស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ សាលាដំបូងរាជធានី-ខេត្ត និងបន្តរៀបចំបោះពុម្ពផ្សាយនូវព្រឹត្តប័ត្រលេខ០៤ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅលើប្រធានបទៈកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅយប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០

-បានធ្វើសិក្ខាសាលានៅខេត្តព្រះសីហនុ រយៈពេលពីរថ្ងៃ ដើម្បីបន្តការធ្វើផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំ(២០០៩-២០១៣) និងផែនការការងាររបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពីថ្ងៃទី ០៣-០៥ ខែមីនា ឆ្នាំ២០១០

-ចូលរួមធ្វើជាវាគ្មិនកិត្តិយសនៅវិទ្យុ FM102 $MH_2$ មណ្ឌលព័ត៌មានស្ត្រីកម្ពុជាទៅលើប្រធានបទៈ ***តុលាការគំរូ*** នៅកម្ពុជា នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០

-រៀបចំនឹងធ្វើបច្ចុប្បន្នភាព គេហទំព័រក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**គ. ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ**

-បានធ្វើការសិក្សាស្រាវជ្រាវវាយតម្លៃ និងរៀបចំសិក្ខាសាលាផ្សេងៗ ទាក់ទងដល់ការបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិនៅកម្ពុជា (A2J)

-បានប្រជុំរវាងក្រសួងស្ថាប័នពាក់ព័ន្ធពិភាក្សាលើសំណើក្របខ័ណ្ឌនៃការអនុវត្តប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-បានបន្តប្រជុំពិភាក្សារៀបចំផែនការយុទ្ធសាស្ត្រ និងផែនការការងាររបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០

-បានប្រជុំក្រុមការងារបច្ចេកទេសចម្រុះ (TWG) សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការតាមកាលកំណត់រៀងរាល់ពីរខែ ជាមួយក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា

-បានរៀបចំសិក្ខាសាលាពិនិត្យឡើងវិញនូវការអនុវត្ត កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ និងចុះធ្វើទំនាក់ទំនងតាមក្រសួងស្ថាប័នស្រង់ព័ត៌មានពាក់ព័ន្ធ

-បានប្រជុំរៀបចំសៀវភៅកម្រងព័ត៌មានសេវាយុត្តិធម៌ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធកាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០

-បានប្រជុំរៀបចំសូចនាករតាមដានរួម (JMIs) ប្រចាំឆ្នាំ២០១០

-ចុះជួបជាមួយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ ជួបជាមួយក្រសួងយុត្តិធម៌ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ ក្រសួងមហាផ្ទៃនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០ និងចុះទៅជួបតុលាការគំរូខេត្តកំពង់ចាមនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ដើម្បីស្វែងយល់អំពីការងារមួយចំនួនពាក់ព័ន្ធដល់ការពិនិត្យឡើងវិញនូវកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ និងការប៉ាន់តម្លៃសម្រាប់ការអនុវត្តជាអាទិភាពរបស់ កកចយ

-ប្រជុំក្រុមប្រតិបត្តិគម្រោង និងពិនិត្យរបាយការណ៍វាយតម្លៃបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា( A2J ) នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០

-ជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធក្នុងការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ A2J ( UNDP,MoI,MoJ, CLJR)

-ពិភាក្សាអំពីការរៀបចំសន្និសីទស្តីពី ( ADR ) នៅកម្ពុជានៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០

-ពិភាក្សាវិភាគព័ត៌មានសម្រាប់ការធ្វើបច្ចុប្បន្នកម្ម កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំផែនការចរិកាសម្រាប់ឆ្នាំ២០១០ របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-ប្រជុំក្រុមការងារតាក់តែងកម្រងព័ត៌មានសេវាសាធារណៈ (ចង្កោមទី៣ពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល)

-ប្រជុំពិភាក្សាលើកិច្ចការពាក់ព័ន្ធតុលាការគំរូនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ នៅសាលប្រជុំទីស្តីការក្រសួងយុត្តិធម៌

-កែសម្រួលមគ្គុទ្ទេសផែនការ សម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួង

-ចូលរួមគ្រប់ក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

-ទទួលជួបជាមួយលោក Lee Kiyoung រដ្ឋអាជ្ញាក្រសួងយុត្តិធម៌ដើម្បីស្វែងយល់ពីការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងតួនាទីរបស់ក្រសួងយុត្តិធម៌

-ចូលរួមសន្និសីទអន្តរជាតិ ស្តីពីកិច្ចសហប្រតិបត្តិការជាសាកល ដើម្បីជំរុញអភិបាលកិច្ចល្អនៅទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុនរយៈពេលបីថ្ងៃ ពីថ្ងៃទី២១ ដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០

-ចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងសម្ភាសន៍របស់វិទ្យុអាស៊ីសេរី ទៅលើប្រធានបទៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីយប់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១០

-ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមៈ១-សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និង២-បញ្ហាផ្សេងៗ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០

-ចូលរួមជាអធិបតីក្នុងពិធីសម្ពោធន៍ "សៀវភៅណែនាំពីការសម្រុះសម្រួល និងសៀវភៅណែនាំប្រតិបត្តិការសម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ស្រុក និងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់" ដែលរៀបចំដោយស្រួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគាសាន់វ៉េ ភ្នំពេញ។

-ចូលរួមសិក្ខាសាលា ស្តីពី"ការធីសម្ពោធឯកសារចងក្រងវិធានប្រពៃណីជនជាតិដើមភាគតិច" ដែលរៀបចំដោយគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។

-ចូលរួមសិក្ខាសាលាស្តីពីការបង្ហាញសមិទ្ធិផលនៃការអនុវត្តកម្មវិធី "ពង្រឹងសមត្ថភាព សន្ទនាសហគមន៍"នាថ្ងៃទី៣0 ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារអ៊ុមភីរៀ

-ចូលរួមស្តាប់របាយការណ៍បណ្តោះអាសន្ន ស្តីពីការវាយតម្លៃចុងក្រោយលើគម្រោងសិទ្ធិទទួលបានយុត្តិធម៌ដែលរៀបចំដោយអង្គការ យូអិនឌីភី នៅភោជនីយដ្ឋានបៃតងភ្នំពេញ កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០

-ចូលរួមប្រជុំប្រចាំឆ្នាំលើទី៣ នៃកិច្ចសហប្រតិបត្តិការកម្ពុជា-អាមេរិក កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ចូលរួមក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (The 3st CDCF meeting) នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១០ នៅវិមានរាជរដ្ឋាភិបាល

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទទួលជួប ឯកឧត្តម (Surya Prasad Subedi) អ្នកសរសេររបាយការណ៍ពិសេសរបស់ **អ.ស.ប** ទទួលបន្ទុកការងារសិទ្ធិមនុស្សនៅកម្ពុជាចូលជួបសវនាការ ដើម្បីពិភាក្សាលើការរៀបចំ នឹងការប្រព្រឹត្តទៅរបស់ប្រព័ន្ធតុលាការ ការទទួលបានយុត្តិធម៌របស់ ពលរដ្ឋ និងសមត្ថភាពផ្តល់យុត្តិធម៌ឱ្យពួកគេ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០ នៅសាលប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី

## ២.សន្និដ្ឋាន

ក្នុងខែឆមាសទី១ នៃឆ្នាំ២០១០ នេះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានអនុវត្តការងារ និងបានសម្រេចនូវការងារមួយចំនួនមានៈ បានប្រជុំពិភាក្សាបញ្ចប់របាយការណ៍ស្តីពីសំណើក្របខ័ណ្ឌនៃការអនុវត្តន៍ប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា បញ្ចប់ការធ្វើផែនការយុទ្ធសាស្ត្រ និងផែនការការងាររបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើៈការរៀបចំនូវផែនការយុទ្ធសាស្ត្រ និងផែនការការងារសម្រាប់ការអនុវត្តភារកិច្ចរបស់ខ្លួន និងការពិនិត្យរៀបចំធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌សម្រាប់ឆ្នាំ២០០៩-២០១៣ និងបន្តជំរុញតាក់តែងកម្រងសេវាសាធារណៈ (ចង្កោមទី៣ ពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល)។

## ៣.ទិសដៅអនុវត្តបន្ត

-បញ្ចប់ការរៀបចំផែនការការងារសម្រាប់ផ្នែកផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-ប្រជុំពិនិត្យសេចក្តីព្រាងសំណើក្របខ័ណ្ឌបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា

-បញ្ចប់ការងារបច្ចុប្បន្នកម្មកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការបច្ចុប្បន្នកម្ម ២០១០-២០១៣

-បន្តការងាររៀបចំកម្រងសេវាព័ត៌មានទាក់ទងវិស័យដល់វិស័យយុត្តិធម៌

-បន្តពិនិត្យលើការបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

-តាមដានការអនុវត្តគម្រោងតុលាការគំរូ

-ស្វែងយល់អំពីស្ថានភាពរបស់រដ្ឋបាលនៅតាមតុលាការ

-ធ្វើការទាក់ទងជាមួយសហគមន៍អឺរ៉ុប ដើម្បីស្វែងយល់អំពីជំនួយដល់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-សហការជាមួយ(DIHR)ដើម្បីកែលំអរផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋានកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការធ្វើបច្ចុប្បន្ន។

*រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមិថុនាឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

ស៊ុន សិរីវុធ

**ស៊ុយ ម៉ុងលាង**